# ទទួលការចាក់ដូសជំរុញបង្ការកូវីដ-19 របស់អ្នក





MAINE IMMIGRANTS' RIGHTS COALITION

## តើការចាក់ដូសជំរុញបង្ការកូវីដ-19 ជាអ្វី?

ការចាក់ដូសជំរុញបង្ការកូវីដ-19 គឺជាការចាក់វ៉ាក់សាំងមួយដូសបន្ថែមទៀត ដែលជួយពង្រឹងប្រព័ន្ធភាពស៊ាំរបស់អ្នក និងផ្តល់ឱ្យអ្នកនូវការការពារបន្ថែមប្រឆាំងនឹងកូវីដ-19។

## តើខ្ញុំអាចទទួលការចាក់ដូសជំរុញនៅពេលណា?

សម្រាប់បុគ្គលដែលបានទទួលវ៉ាក់សាំងកូវីដ-19 Pfizer-BioNTech ឬ Moderna ក្រុមខាងក្រោមនេះមានសិទ្ធិទទួលការចាក់ដូសជំរុញនៅរយៈពេលចាប់ពី 6 ខែឡើងទៅ បន្ទាប់ពីស៊េរីដំបូងរបស់ពួកគេ៖

- អាយុ 65 ឆ្នាំឡើងទៅ
- អាយុ 18+ ដែលរស់នៅក្នុងកន្លែងថែទាំរយៈពេលវែង
- អាយុ 18+ ដែលមានបញ្ហាសុខភាព
- អាយុ 18+ ដែលធ្វើការ ឬរស់នៅក្នុងកន្លែងដែលមានហានិភ័យខ្ពស់

ការចាក់ដូសជំរុញត្រូវបានណែនាំសម្រាប់អ្នករាល់គ្នាដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅយ៉ាងហោចណាស់នៅរយៈពេល 2 ខែបន្ទាប់ពីចាក់វ៉ាក់សាំងកូវីដ-19 J&J/Janssen រួចហើយ។

## តើខ្ញុំអាចទទួលការចាក់ដូសជំរុញនៅទីណា?

បណ្តាញចាក់វ៉ាក់សាំងសហគមន៍ជួយប្រជាជនរដ្ឋ Maine ស្វែងរកវ៉ាក់សាំងកូវីដ-19 ដែលនៅជិតអ្នកបានលឿន។

ទូរសព្ទ៖ 1-888-445-4111

ច័ន្ទដល់សុក្រ ម៉ោង 9 ព្រឹកដល់ 5:30 ល្ងាច

សម្រាប់សេវាបកប្រែ សូមទូរសព្ទទៅលេខ ហើយបញ្ជាក់ភាសាដែលអ្នកចង់បាន។

## តើមានមធ្យោបាយដឹកជញ្ជូនទេ?

មាន ប្រសិនបើត្រូវការមធ្យោបាយដឹកជញ្ជូន សូមទូរសព្ទ ផ្ញើសារ ឬអ៊ីមែលទៅកាន់ MANA៖

ឬ ទូរសព្ទទៅលេខ 1-855-608-5172 (ModivCare)

## តើខ្ញុំអាចចាក់លាយ និងឆ្លងវ៉ាក់សាំងបានទេ?

បាន

មនុស្សមួយចំនួនអាចមានចំណូលចិត្តចំពោះប្រភេទវ៉ាក់សាំងដែលពួកគេបានទទួលពីដំបូង ឯអ្នកផ្សេងទៀតអាចចូលចិត្តទទួលដូសជំរុញប្រភេទផ្សេង។ ឥឡូវនេះ CDC មានសេចក្តីណែនាំអនុញ្ញាតឱ្យមានការចាក់លាយ និងឆ្លងប្រភេទនេះបានសម្រាប់ការចាក់ដូសជំរុញ។

## តើខ្ញុំអាចចាក់ដូសជំរុញបង្ការកូវីដ-19 និងថ្នាំបង្ការផ្តាសាយក្នុងពេលតែមួយបានឬទេ?

បាន វ៉ាក់សាំងផ្តាសាយ និងកូវីដ-19 អាចត្រូវបានចាក់ក្នុងពេលតែមួយ។

## តើការចាក់ដូសជំរុញឥតគិតថ្លៃឬទេ? តើខ្ញុំត្រូវការធានារ៉ាប់រងសុខភាពឬទេ?

បាទ/ចាស ការចាក់ដូសជំរុញបង្ការកូវីដ-19 គឺមិនគិតថ្លៃទេ។

ទេ មិនត្រូវការធានារ៉ាប់រងសុខភាពទេ។

គេនឹង មិន សួរអ្នកអំពីឋានៈអន្តោប្រវេសន៍របស់អ្នកឡើយ។